# Annual School Report
# Frequently Asked Questions
# របាយការណ៍សាលាប្រចាំឆ្នាំ
# សំណួរនានាទូលាយដែលគេតែងសួរជាញឹកញាប់

## តើរបាយការណ៍សាលាប្រចាំឆ្នាំជាអ្វី?

របាយការណ៍សាលាប្រចាំឆ្នាំ គឺជាកំណត់ត្រាស្តីអំពីដំណើរការវាយតម្លៃដោយខ្លួនឯងរបស់សាលារៀន។ របាយការណ៍នេះត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ហើយជាផ្នែកមួយនៃការវិលចុះវិលឡើងជាបន្តបន្ទាប់នៃការវាយតម្លៃ និងគំរោងការរបស់សាលារៀន។

របាយការណ៍សាលាប្រចាំឆ្នាំផ្តល់នូវព័ត៌មានទៅដល់សហគមន៍សាលា ស្តីអំពីការបំពេញមុខការរបស់សាលារៀននៅក្នុងកម្មវិធីធ្វើតេស្តទូទាំងរដ្ឋ និងក្នុងប្រទេស។ វាក៏ផ្តល់នូវព័ត៌មានផងដែរអំពីទស្សនមាននៅក្នុងព័ត៌មានដែលត្រូវគេយកមកវាស់ស្ទង់។

មានសាលារៀន និងមជ្ឈមណ្ឌលអប់រំប្រមាណជា២២៥០កន្លែងរៀបចំរបាយការណ៍សាលាប្រចាំឆ្នាំ ស្របទៅតាមល័ក្ខខ័ណ្ឌបង្កើតឡើងដោយ NSW Department of Education and Training (DET) (ក្រសួងបណ្តុះបណ្តាល និងអប់រំរដ្ឋញូវសៅវែល) និងក្រុមប្រឹក្សាទទួលខុសត្រូវលើការវាស់ស្ទង់ការអប់រំ និងសាលារៀន (Educational Measurement and School Accountability Directorate)។

## តើអ្វីជាគោលបំណងនៃរបាយការណ៍សាលាប្រចាំឆ្នាំ?

របាយការណ៍សាលាប្រចាំឆ្នាំ គឺជាសមាភាគដ៏សំខាន់នៃតម្រូវការទទួលខុសត្រូវរបស់សាលារៀនទៅដល់មាតាបិតា និងសហគមន៍របស់ខ្លួនទៅដល់ NSW Department of Education and Training (DET) ហើយនិងក្រសួងអប់រំ ការងារ និងទំនាក់ទំនងកន្លែងធ្វើការរបស់រដ្ឋាភិបាលសហព័ន្ធ (Department of Education, Employment and Workplace Relations) (DEEWR)។

## តើមានតម្រូវការធ្វើរបាយការណ៍ចាំបាច់អ្វីខ្លះ សំរាប់របាយការណ៍សាលាប្រចាំឆ្នាំ?

គោលគ្រឹះចាំបាច់ដែលសាលារៀនត្រូវបានតម្រូវ ដើម្បីរាយការណ៍យ៉ាងធំទូលាយគ្របដណ្តប់ដូចតទៅនេះ:

- ព័ត៌មានអំពីប្រវត្តិរបស់បុគ្គលិកសាលា និងសិស្ស
- ការរៀនសូត្ររបស់សិស្ស
- ការវាយតម្លៃដោយខ្លួនឯងរបស់សាលារៀន
- ទិសដៅដើម្បីកែលំអ។

## តើនរណាទទួលខុសត្រូវចំពោះការបង្កើតរបាយការណ៍សាលាប្រចាំឆ្នាំ?

របាយការណ៍សាលាប្រចាំឆ្នាំត្រូវបានរៀបចំដោយគណៈកម្មការវាយតម្លៃដោយខ្លួនឯងរបស់សាលារៀន។ គណៈកម្មការមានរួមដោយអ្នកតំណាងសហគមន៍ និងមាតាបិតា គ្រូបង្រៀន និងសមាជិកបុគ្គលិកប្រតិបត្តិនៅក្រោមការដឹកនាំរបស់នាយកសាលា។

## តើគ្រប់សាលារៀនត្រូវបានតម្រូវឲ្យបង្កើតរបាយការណ៍សាលាប្រចាំឆ្នាំឬ?

ពិតមែនហើយ។ គ្រប់សាលារៀនរដ្ឋញូវសៅវែលទាំងអស់ បានតម្រូវឲ្យបង្កើតរបាយការណ៍សាលាប្រចាំឆ្នាំចាប់តាំងពីឆ្នាំ 1997 មកម្លេះ។

## តើព័ត៌មានអ្វីខ្លះដែលខ្ញុំអាចរំពឹងទុកថានឹងបានអាននៅក្នុងរបាយការណ៍សាលាប្រចាំឆ្នាំ?

របាយការណ៍សាលាប្រចាំឆ្នាំមានរួមទាំងព័ត៌មានអំពី:

- ព័ត៌មានសង្ខេបរបស់បុគ្គលិកសាលា និងសិស្ស
- លទ្ធផលនៃការសិក្សារបស់សិស្សនៅក្នុងការធ្វើតេស្តពេញទូទាំងរដ្ឋ និងក្នុងប្រទេស ទាំងនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា
- ការសំរេចជោគជ័យលើការសិក្សាក្នុងផ្នែកសិល្បៈ និងកីឡា
- ព័ត៌មានទាក់ទិននឹងកម្មវិធី និងការផ្តួចផ្តើមសំខាន់ៗផ្តល់ដោយសាលារៀន
- ការវាយតម្លៃដោយខ្លួនឯងរបស់សាលារៀនលើទិសដៅ និងការចំរើនលើការសិក្សា និង
- ទិសដៅដើម្បីកែលំអសំរាប់ឆ្នាំខាងមុខ។

## តើក្រុមសាលារៀនដូចគ្នា (Like School Group) (LSG) ជាអ្វី?

Like School Group គឺជាក្រុមសាលារៀនដែលស្រដៀងគ្នាតាមមូលដ្ឋាននៃកត្តាសហគមន៍ចំនួនពីរ មានរួមទាំងៈ

- ស្ថានការណ៍សេដ្ឋកិច្ចសង្គមជាមធ្យមនៃសហគមន៍សាលារៀន (ស្ថានការណ៍សេដ្ឋកិច្ចសង្គមសាលារៀន គឺជាការវាស់ស្ទង់ដែលត្រូវបានគណនារៀងរាល់ឆ្នាំសិក្សា ដើម្បីឆ្លុះបញ្ចាំងទៅលើការផ្លាស់ប្តូរនៅក្នុងលំនាំការចុះឈ្មោះចូលរៀន)។
- ការនៅដាច់ពីគេឯងតាមភូមិសាស្ត្រ។

គ្រប់សាលាបឋមសិក្សា មធ្យមសិក្សា និងសាលាបឋមថ្នាក់ខ្ពស់ ត្រូវបានលៃទុកទៅក្នុង Like School Groups ១នៃក្រុមសាលារៀនដូចគ្នា៩ លើកលែងតែគេជាសាលាមធ្យមសិក្សាជ្រើសសំរាំង។ Like School Group បន្ថែមត្រូវបានរៀបចំឲ្យមានសំរាប់សាលាមធ្យមសិក្សាជ្រើសសំរាំង។

សាលារៀនអាចជ្រើសរើសធ្វើរបាយការណ៍អំពីការបំពេញមុខការរបស់គេ នៅក្នុងរបាយការណ៍សាលាប្រចាំឆ្នាំ ក្នុងទំនាក់ទំនងទៅនឹងការបំពេញមុខការនៃ Like School Group (LSG) របស់ខ្លួន។

ការធ្វើរបាយការណ៍អំពីការបំពេញមុខការក្នុងការប្រៀបធៀបជាមួយនឹង Like School Group មិនមែនជាការដែលត្រូវធ្វើដោយខានពុំបានឡើយ។ សាលារៀនអាចជ្រើសរើសចុះផ្សាយព័ត៌មាននេះ ដើម្បីបង្ហាញប្រាប់ពីបែបយ៉ាងណាដែលសាលារៀនរបស់ខ្លួនបំពេញមុខការ នៅក្នុងការវាយតម្លៃពេញទូទាំងរដ្ឋ ប្រៀបធៀបទៅនឹងសាលារៀនឯទៀតមកពី Like School Group ដូចគ្នា។ ជួនកាលការនេះអាចមានប្រយោជន៍ជាងការប្រៀបធៀបលទ្ធផលជាមួយនឹងលទ្ធផលមធ្យមក្នុងរដ្ឋ។

## តើតម្រូវការធ្វើរបាយការណ៍សំរាប់សាលារៀនតូច ដូចគ្នានឹងសាលារៀនធំដែរឬ?

ចំពោះក្រុមសាលារៀនតូច ឬក្រុមសិស្សតូច ការធ្វើរបាយការណ៍នៃព័ត៌មានត្រូវស្របទៅតាមគោលការណ៍ព័ត៌មានភាពឯកជន និងផ្ទាល់ខ្លួន។ ស្ថិតិសង្ខេប ឬការតំណាងជាគំនូសតាងនៃការរៀនសូត្ររបស់សិស្ស មិនត្រូវប្រើសំរាប់ក្រុមនៃសិស្សដែលមានចំនួនតិចជាង១០នាក់នៅក្នុងវគ្គសិក្សា ឬមុខវិជ្ជាណាមួយឡើយ។ កន្លែងណាដែលមានសិស្សតិចជាង១០នាក់ សាលារៀននឹងធ្វើរបាយការណ៍អំពីព័ត៌មានជាពាក្យរៀបរាប់ប៉ុណ្ណោះ ហើយដោយមានការប្រុងប្រយ័ត្នដើម្បីប្រាកដឲ្យបានច្បាស់ទៅលើភាពឯកជននៃសិស្សទាំងអស់។

## តើមានជំរើសតម្រូវការធ្វើរបាយការណ៍អ្វីខ្លះ?

សាលារៀនបានផ្តល់ឲ្យមានជំរើសដើម្បីដាក់បញ្ចូលនូវព័ត៌មានទាក់ទិនទៅនឹងការទទួលស្គាល់ ទៅលើការសំរេចជោគជ័យលើការសិក្សាយ៉ាងល្អរបស់សិស្ស នៅក្នុងមុខវិជ្ជាសិល្បៈ កីឡា ភាពជាសញ្ជាតិ ហើយនិងផ្នែកសិក្សាឯទៀតទាក់ទិននឹងសាលារៀនរបស់គេ។

ព័ត៌មានសង្ខេបទាក់ទិននឹងកម្មវិធីសាលារៀនឯទៀតដែលមានផ្តល់ ក៏អាចដាក់បញ្ចូលផងដែរដូចជាផ្នែកសុខុមាលភាពសិស្ស ព័ត៌មាន និងការទាក់ទងផ្នែកបច្ចេកវិទ្យា ការអប់រំ និងកម្មវិធីផ្នែកបរិដ្ឋានសំរាប់សិស្សដែលមានសេចក្តីត្រូវការបន្ថែម។

## តើពេលណាដែលខ្ញុំអាចរំពឹងទុក ថានឹងបានទទួលរបាយការណ៍សាលាប្រចាំឆ្នាំមួយច្បាប់សំរាប់សាលារៀនរបស់កូនខ្ញុំ?

ជាទូទៅ សាលារៀនផលិតរបាយការណ៍សាលាប្រចាំឆ្នាំរបស់ខ្លួននៅក្នុងត្រីមាសទី១ និងទី២នៃឆ្នាំបន្ទាប់។ នេះគឺជាតម្រូវការដែលថារបាយការណ៍សាលាប្រចាំឆ្នាំត្រូវបានចែកចាយឲ្យបានទាន់ថ្ងៃទី៣០ ខែមិថុនា រៀងរាល់ឆ្នាំ។

## តើខ្ញុំទទួលយករបាយការណ៍សាលាប្រចាំឆ្នាំមួយច្បាប់ សំរាប់សាលារៀនរបស់កូនខ្ញុំដោយបែបណា?

សាលារៀននឹងផ្តល់របាយការណ៍បោះពុម្ពមួយច្បាប់ ទៅឲ្យគ្រួសារនីមួយៗដែលមានសិស្សរៀននៅសាលារៀនរបស់ខ្លួន។ សាលារៀនជាច្រើនជ្រើសរើសផ្តល់របាយការណ៍សាលាប្រចាំឆ្នាំតាមបែបអេឡិកត្រូនិក ដោយដាក់របាយការណ៍នៅតាមវិបសាយរបស់សាលារៀន។ សូមទាក់ទងជាមួយសាលារៀនរបស់កូនលោកអ្នក ឬ Educational Measurement and School Accountability Directorate តាមទូរស័ព្ទលេខ 9707 6217 ដើម្បីទទួលយកព័ត៌មានបន្ថែមអំពីរបៀបទទួលយករបាយការណ៍នេះមួយច្បាប់។

## កិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសាដើម្បីជួយលោកអ្នកទាក់ទងជាមួយសាលារៀនរបស់កូនលោកអ្នក ឬជាមួយ Educational Measurement and School Accountability Directorate សូមទូរស័ព្ទទៅកិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទលេខ 131 450 រួចស្នើសុំជួបអ្នកបកប្រែជាភាសារបស់លោកអ្នក។ អ្នកបកប្រែភាសានឹងទូរស័ព្ទទៅសាលារៀន ឬ Directorate ហើយនឹងរក្សានៅជាប់តាមទូរស័ព្ទ ដើម្បីជួយលោកអ្នកនៅក្នុងការសន្ទនារបស់លោកអ្នក។ គេនឹងមិនគិតថ្លៃកិច្ចបំរើនេះពីលោកអ្នកឡើយ។

NEW SOUTH WALES DEPARTMENT OF EDUCATION AND TRAINING